រក្សាសិទ្ធិ © ពត៌មាន :
© ២០០៩ Project WorldReach © ២០០៩ SEAN
រក្សាសិទ្ធិគ្រប់យ៉ាង

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

Project WorldReach (T&M™ ព័ន្ធកិច្ចប្រតិបត្តិការ)
Dr. George Patterson, (អ្នកនិពន្ធកម្មវិធី)
SEAN អន្តរជាតិ

អាស័យដ្ឋានសំរាប់ទាក់ទង :
Project WorldReach PWR ™
474 - 800 - 15355 - 24th Ave
Surrey BC, Canada
V4A 2H9

E-mail: pwr@trainandmultiply.com
Website: http://www.trainandmultiply.com

016KH01A-01

ព្រះយេស៊ូវគ្រីស្តឈ្នះលើមារសត្វរបស់យើង



កូនស្បៃរំភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល

១៦

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

T&M ™

រឿងនេះបានចាប់ផ្តើមឡើងនៅស្ថានបរមសុខ...



ពួកទេវទូតកំពុងថ្វាយបង្គំព្រះជាម្ចាស់ដ៏វិសុទ្ធបំផុត ។

កំណត់ចំណាំ :

© Project WorldReach © SEAN

๒๑- តើមនុស្សតែម្នាក់ គឺព្រះយេស៊ូគ្រីស្តអាចសង្គ្រោះមនុស្ស យ៉ាងច្រើន ដែលជឿលើព្រះអង្គបាន ដោយរបៀបណា ? សូមសរសេរចំលើយរបស់អ្នក :

_____

_____

_____

កិច្ចការដែលត្រូវអនុវត្ត

- បង្រៀនក្រុមជំនុំ និងមិត្តភក្តិរបស់អ្នកអំពីរឿងរ៉ាវនៃការធ្លាក់ចុះរបស់មនុស្សទៅក្នុងអំពើបាប និង សេចក្តីស្លាប់ ហើយ និងពីរបៀបដែលព្រះអម្ចាស់យេស៊ូឈ្នះលើមារសាតាំង និង ប្រទានជីវិតអស់កល្បដល់យើង ។ អ្នកអាចប្រើកូនសៀវភៅនេះ សំរាប់បំភ្លឺក្នុងបង្រៀនបាន ។
- *«សូមផ្សព្វផ្សាយដំណឹងល្អ»* (២ ធីម៉ូថេ ៤:៥) ។ សូមពន្យល់ប្រាប់ពួកអ្នកជិតខាងរបស់អ្នក ដែលមិនទាន់បានសង្គ្រោះ អំពី «ដំណឹងល្អ» ។



© Project WorldReach © SEAN

រំពេចនោះ ទេវទូតលូស៊ីហ្វើដែលមានរូបសម្ផស្សស្អាតដាច់គេ ក៏លែងគោរពថ្វាយបង្គំព្រះជាម្ចាស់ ដោយមានគំនិតថា...

ហេតុអ្វីក៏ព្រះអង្គត្រូវទទួលសិរីរុងរឿងទាំងអស់នេះ ? មើលចុះ ! ខ្ញុំមានរូបស្នាតណាស់ ! ខ្ញុំនឹងឡើងទៅលើមេឃ ហើយលើកបល្ល័ង្ករបស់ខ្ញុំឡើងអោយខ្ពស់ជាងផ្កាយរបស់ព្រះជាម្ចាស់ទៅទៀត ។ ខ្ញុំនឹងធ្វើអោយខ្លួនខ្ញុំស្មើនឹងព្រះជាម្ចាស់ដ៏ខ្ពស់បំផុត ។
(អេសាយ ១៤:១២-១៤)



១៨- ពួកអារក្សដែលបានទទួលទោស ធ្លាក់ទៅស្ថាននរកជារៀងរហូត ជា :

☐ ព្រលឹងមនុស្សស្លាប់ ។

☐ ទេវទូតអាក្រក់ដែលបាត់បង់សិរីរុងរឿង ។

១៩- ពួកទេវទូតដែលធ្លាក់ចុះទាំងនោះ បានបាត់បង់សេចក្តីសង្ឃឹមអស់ហើយ ។ ប៉ុន្តែ សេចក្តីសង្ឃឹមតែមួយរបស់មនុស្សដែលមានបាប គឺ :

☐ ការសង្គ្រោះ ដោយសារព្រះអម្ចាស់យេស៊ូគ្រីស្តរបស់យើង ។

☐ ជីវិតរស់នៅដោយសុចរិត ។

២០- យើងអាចទទួលការសង្គ្រោះអស់កល្បនេះ តាមរយៈព្រះ-គ្រីស្ត ដោយ :

☐ យើងប្រព្រឹត្តល្អ ។

☐ យើងជឿលើព្រះយេស៊ូគ្រីស្ត ។

© Project WorldReach © SEAN



១៥- មនុស្សម្នាក់ (អាដាម) មិនស្តាប់បង្គាប់ បណ្តាលអោយ :

- ☐ សេចក្តីស្លាប់ និង អំពើបាបឆ្លងរាលដាលដល់មនុស្សទាំងអស់ ។
- ☐ សេចក្តីស្លាប់ និង អំពើបាបឆ្លងរាលដាលដល់តែកូនៗផ្ទាល់របស់អាដាមប៉ុណ្ណោះ ។

១៦- ដោយសារព្រះយេស៊ូស្តាប់បង្គាប់ ទើបពួកអ្នកជឿលើព្រះអង្គ :

- ☐ បានព្រះជាម្ចាស់រាប់ជាសុចរិត និងបានផ្សះផ្សាជានានឹងព្រះអង្គវិញ ។
- ☐ មានសំណាងល្អ ។

១៧- ព្រះគ្រីស្តដែលមានព្រះជន្មរស់ឡើងវិញបានរំដោះយើងដោយសារព្រះលោហិតរបស់ព្រះអង្គ និង ចែកចាយជីវិតអស់កល្បជានិច្ចរបស់ព្រះអង្គដល់ប្រជារាស្ត្ររបស់ព្រះអង្គ ។ ពួកអ្នកដែលមិនជឿលើព្រះគ្រីស្ត នឹងរស់ឡើងវិញដើម្បី :

- ☐ ទទួលទោស ។
- ☐ មានជីវិតអមតៈ (រស់ជារៀងរហូត) ។

ព្រះជាម្ចាស់បានឃោះបង់ចោលពួកទេវទូត ដែលបះបោរទាំងនោះ ដោយទំលាក់គេចេញពីស្ថានបរមសុខ ។



« ដ្បិតព្រះជាម្ចាស់ពុំបានយោគយល់ដល់ពួកទេវទូតដែលប្រព្រឹត្តអំពើបាបទេ ទ្រង់បានរុញពួកគេទម្លាក់ទៅក្នុងនរកអវិចី ដែលងងឹតសូន្យ ហើយគេជាប់ឃុំឃាំងនៅទីនោះ រង់ចាំពេលព្រះអង្គវិនិច្ឆ័យទោស » ។ (២ ពេត្រុស ២:៤)

១៣- ដោយសារព្រះយេស៊ូបានស៊ូប្តូរប្រទានជីវិតព្រះអង្គ ព្រះ-យេស៊ូបានកំទេចអំណាចរបស់មារសាតាំង ដែលមានលើប្រជារាស្ត្ររបស់ព្រះជាម្ចាស់ ដោយ :

☐ ព្រះអម្ចាស់បានចេញថ្លៃលោះអំពើបាបរបស់យើង ហើយឥឡូវនេះ អារក្សគ្មានអ្វីអាចចោទប្រកាន់យើងទៀតទេ ។

☐ អារក្សកែប្រែចិត្តគំនិត ។

១៤- ព្រះយេស៊ូចេញថ្លៃសងអំពើបាប ហើយលុបបំបាត់អំណាចរបស់មារសាតាំង ដែលមានលើមនុស្សយើង ។ ព្រះអង្គបើកផ្លូវសំរាប់ចូលទៅក្នុងវត្តមានរបស់ព្រះជាម្ចាស់ ដោយសារ :

☐ ទ្រព្យសម្បត្តិរបស់ព្រះអង្គ ។

☐ ព្រះលោហិតរបស់ព្រះអង្គ ។

១០- យូដាសក្បត់ព្រះអម្ចាស់យេស៊ូគ្រីស្ត ។ ព្រះយេស៊ូជា :

☐ ទេវទូត ។

☐ បុត្រារបស់ព្រះជាម្ចាស់ ។

☐ គ្រាន់តែជាមនុស្សល្អម្នាក់ប៉ុណ្ណោះ ។

១១- នៅពេលដែលព្រះយេស៊ូសុគត :

☐ ផែនការរបស់ព្រះជាម្ចាស់ ត្រូវពន្យារពេលមិនទាន់បានសំរេច ។

☐ ផែនការរបស់ព្រះជាម្ចាស់បានសំរេច ។

១២- មនុស្សខ្លះនិយាយថា ព្រះយេស៊ូមានកម្មអាក្រក់ ព្រោះព្រះអង្គសុគតលើឈើឆ្កាង ។ តែតាមពិត ព្រះយេស៊ូ :

☐ មិនចង់សុគតទេ តែព្រះអង្គទន់ខ្សោយពេក មិនអាចជួយព្រះអង្គឯងបាន ។

☐ ស្ម័គ្រព្រះទ័យប្រទានជីវិតព្រះអង្គ ជាយញ្ញបូជា ដើម្បីលោះបាបយើងទៅវិញ ។

សម្តែងរបស់ព្រះជាម្ចាស់បានបន្លឺឡើងយ៉ាងខ្លាំងក្លា ធ្វើឱ្យរញ្ជួយផ្ទៃមេឃ និង ផែនដី...

ម្តេចក៏អ្នកធ្លាក់ពីលើមេឃមកដូច្នេះ លូស៊ីហ្វើ អ្នកបែរជាធ្លាក់ចុះមកដល់ស្ថានមច្ចុរាជ គឺក្នុងរណ្តៅដ៏ជ្រៅនេះទៅវិញ! (អេសាយ ១៤:១២-១៥) ។



តែមារសាតាំងបន្តធ្វើការប្រយុទ្ធដ៏ឆ្កួតលីលាតទៅទៀត ...



៧- ដើម្បីអោយមនុស្សអាចគេចផុតពីការដាក់ទោសជារៀងរហូតរបស់ព្រះជាម្ចាស់ និង ពី « សេចក្តីស្លាប់លើកទីពីរ » មនុស្សត្រូវមានជីវិតថ្មីក្នុង :

☐ ពិធីជ្រមុជទឹក ។

☐ ព្រះយេស៊ូជាព្រះបុត្រារបស់ព្រះជាម្ចាស់ ។

៨- មនុស្សដែលគ្មានព្រះគ្រីស្ត មិនអាចចូលទៅក្នុងវត្តមានរបស់ព្រះជាម្ចាស់បាន ដោយសារតែ :

☐ សេចក្តីស្លាប់ ។

☐ អំពើបាប ។

☐ អារក្ស ។

៩- មានតែអំពើបាបទេ ដែលអាចធ្វើអោយមនុស្សបែកចេញពីព្រះជាម្ចាស់ ។ មារសាតាំងដែលល្បួងមនុស្សអោយធ្វើបាបនេះ បានជំរុញយូដាសអោយ :

☐ ក្បត់ព្រះយេស៊ូ ដើម្បីធ្វើគុតព្រះអង្គ ។

☐ លួចយករបស់ពីក្នុងព្រះវិហារ ។

© Project WorldReach © SEAN

៤- តើអាដាមបានទទួលទោសដូចម្តេច ដោយសារការបរិភោគផ្លែឈើ ដែលព្រះជាម្ចាស់ហាមឃាត់ ?

_____

៥- អំពើបាប និង សេចក្តីស្លាប់ឆ្លងពីអាដាម :

☐ ទៅដល់តែកាអ៊ីនជាកូនរបស់គាត់ប៉ុណ្ណោះ ។

☐ ទៅដល់មនុស្សទាំងអស់ ។

☐ ទៅដល់តែមនុស្សដែលអាក្រក់បំផុតប៉ុណ្ណោះ ។

៦- ដោយសារមនុស្សទាំងអស់ជាមនុស្សបាប មនុស្សក៏ស្លាប់ដោយសារអំពើបាបដើមរបស់អាដាម ។ ក្រោយដែលពួកអ្នកមានបាប ដែលមិនកែប្រែចិត្តគំនិត ស្លាប់ទៅ ពួកគេនឹងត្រូវ :

☐ សាវែកពេត្រុសជំនុំជំរះ ។

☐ ព្រះជាម្ចាស់ជំនុំជំរះ ។

☐ មារសាតាំងជំនុំជំរះ ។



© Project WorldReach © SEAN

មារសាតាំងខ្ញល់ខ្ញាយជាខ្លាំង នៅពេលដែលឮដំណឹងដូច្នោះ...



ការប្រឡង (សំនួរសង្ខេបមេរៀន)

គួសសញ្ញានៅនឹងចំលើយដែលត្រឹមត្រូវ :

១- មុននឹងអារក្សធ្លាក់ចុះ វាជា :

- ☐ ទេវទូតដែលមានរូបស្អាត ។
- ☐ បិសាច ។
- ☐ សត្វពស់ ។

២- ឫសគល់នៃអំពើបាបគ្រប់យ៉ាងគឺ :

- ☐ ដើមឈើដែលនាំអោយស្គាល់ល្អ ស្គាល់អាក្រក់ ។
- ☐ អំនួតរបស់ទេវទូតដែលមានរូបស្អាត ឈ្មោះលូស៊ីហ្វឺ ។

៣- ទេវទូតលូស៊ីហ្វឺដែលធ្លាក់ចុះ បានយករូបភាពជាសត្វពស់ ហើយល្បួងអាដាមដើម្បីអោយអាដាម :

- ☐ ស្រាវជ្រាវពិភពលោក ។
- ☐ បរិភោគផ្លែរបស់ដើមឈើដែលនាំអោយស្គាល់ល្អ ស្គាល់អាក្រក់ ដែលព្រះជាម្ចាស់ហាមឃាត់ ។

ដោយសារយើងបានរួមជាមួយព្រះគ្រីស្ត តាមរយៈព្រះវិញ្ញាណ
របស់ព្រះអង្គ នោះយើងក៏ស្លាប់រួមជាមួយព្រះអង្គ ហើយរស់ឡើង
វិញរួមជាមួយព្រះអង្គ ក្នុងវត្តមានរបស់ព្រះជាម្ចាស់ដ៏វិសុទ្ធបំផុត
ដែរ ។ (រ៉ូម ៦:៣-៦, កូឡូស ៣:១-៣, ហេប្រឺ ៩:១២,
១០:១៩-២០)



ជីវិតអស់កល្បជានិច្ចក្នុងព្រះជាម្ចាស់

សត្រូវរបស់យើង គឺព្រះជាម្ចាស់ បានបង្កើតមនុស្សពី
ធូលីដីរបស់ផែនដី ហើយព្រះអង្គក៏បានបង្កើតគេឱ្យមាន
លក្ខណៈដូចជាព្រះអង្គដែរ ! ព្រះអង្គបានបង្កើតគេជា
បុរស ជាស្ត្រី និងប្រទានពរដល់គេ គឺមនុស្សនោះអាច
និយាយជាមួយព្រះអង្គបាន ហើយគេចេះគិតគូរ និង
មានអារម្មណ៍ថែមទៀតផង ! តែខ្ញុំដឹងកិច្ចការមួយ គឺ
ព្រះអង្គហាមមនុស្សនោះមិនអោយបរិភោគផ្លែរបស់ដើម
ឈើដែលហៅថា “ដើមឈើដែលនាំអោយស្គាល់ល្អ
ស្គាល់អាក្រក់ឡើយ” ។ បើមនុស្សហ៊ានបរិភោគ
ផ្លែនោះ គេមុខជាស្លាប់ជាមិនខាន ពីព្រោះសេចក្តីស្លាប់
គឺជាផលវិបាកនៃការមិនស្តាប់តាមព្រះអង្គ ។



កំណើតពិភពលោក ២:១៧



ព្រះគ្រីស្តជាអាដាមចុងក្រោយ ។ ព្រះអង្គជាយញ្ញបូជា ដើម្បីលោះបាបរបស់ពិភពលោក ។ ពេលដែលយើងកែប្រែចិត្តគំនិតនិងជឿលើព្រះយេស៊ូ យើងនឹងទទួលព្រះវិញ្ញាណរបស់ព្រះអង្គ ។ យើងបានរួមជាមួយព្រះអង្គជារូបកាយតែមួយ ។ (**១ កូរិនថូស ១៥:៤៦-៤៩, រ៉ូម ៥:១៨-១៩**)



តើព្រះយេស៊ូដែលជាមនុស្សតែម្នាក់ អាចសង្គ្រោះមនុស្សជាច្រើនបាន ដោយរបៀបណា ? នេះដូចជារឿងរ៉ាវរបស់អាដាម ដែលជាឪពុករបស់មនុស្សជាតិទាំងមូលដែរ ។

តាមរយៈមនុស្សតែម្នាក់ បាបបានចូលមកក្នុងពិភពលោក ហើយតាមរយៈបាប សេចក្តីស្លាប់ក៏ចូលមកដែរ ។ (រ៉ូម ៥:១២)

អាដាមតំណាងយើងទាំងអស់គ្នា ។ មនុស្សគ្រប់គ្នាបានរួមជាមួយអាដាម និងមានទិស្សុីយពេញដោយអំពើបាបដូចអាដាមដែរ ។ (១ កូរិនថូស ១៥:២២)



នៅក្នុងសួនឧទ្យាននោះ មានដើមឈើដែលនាំអោយស្គាល់ល្អ និងស្គាល់អាក្រក់ ។ ព្រះជាម្ចាស់បញ្ជាមនុស្សថា÷ *«អ្នកមិនត្រូវបរិភោគផ្លែរបស់ដើមឈើដែលនាំអោយស្គាល់ល្អ ស្គាល់អាក្រក់ឡើយ..... ដ្បិតថៃណាអ្នកបរិភោគផ្លែនោះ អ្នកមុខជាស្លាប់មិនខាន»* ។ (កំណើតពិភពលោក ២:១៥-១៧)



មារសាតាំងធ្វើខ្លួនជាសត្វពស់ ។ ដំណើររឿង
ប្រវត្តិសាស្ត្របន្តទៅនេះ ដកស្រង់ពីបទគម្ពីរ
កំណើតពិភពលោក ជំពូក៣ ។



ព្រះអម្ចាស់យេស៊ូបានយាងឡើងទៅគង់នៅខាងស្តាំព្រះបិតា
ហើយព្រះអង្គទូលអង្វរព្រះបិតា ដើម្បីឱ្យយើងមានសេរីភាព
អាចចូលទៅជិតព្រះជាម្ចាស់ ដែលប្រកបដោយសិរីរុងរឿង
ជារៀងរហូត ។ ពាក្យចោទប្រកាន់របស់មារសាតាំង លែង
មានអំណាចលើយើងទៀតហើយ ។

(ហេប្រឺ ២:១៤-១៥)







© Project WorldReach © SEAN



ព្រះយេស៊ូគ្រីស្តត្រូវតែមានព្រះជន្មរស់ឡើងវិញ ដោយសារព្រះអង្គ
ជាព្រះជាម្ចាស់ដ៏ខ្ពស់បំផុត និងដោយសារព្រះអង្គរស់នៅ ដោយ
សុចរិត បានសេចក្តីថា ព្រះយេស៊ូគ្មានបាបទាល់តែសោះ មិនគួរ
ស្លាប់ទេ ។ ឥឡូវនេះ ព្រះអង្គចែកចាយជីវិតថ្មីដ៏នៅអស់កល្ប
របស់ព្រះអង្គ ដល់អស់អ្នកដែលជឿលើព្រះអង្គ ។

(អេភេសូ ២:១-៧)



© Project WorldReach © SEAN

ថៃអាទិត្យ ព្រះអម្ចាស់មានព្រះជន្មរស់ឡើងវិញ ប្រកប
ដោយទ្ធានុភាព និង អំណាច ។



ស្ត្រីនោះមើលទៅផ្លែឈើឃើញថា មានរសជាតិ
ឆាញ់ពិសា ។







ព្រះយេស៊ូកំទេចអំណាចរបស់មារសាតាំង ដោយការសុគតរបស់ព្រះអង្គ ។

«ដោយកូនចៅនោះជាប់សាច់ឈាមជាមួយគ្នា ព្រះអង្គក៏បានយកឋានៈជាមនុស្ស រួមជាមួយគេដែរ ហើយព្រះអង្គសោយទីវង្គត ដើម្បីកំទេចមារដែលមានអំណាចលើសេចក្តីស្លាប់ គឺអារក្ស និង ដើម្បីរំដោះអស់អ្នកដែលនៅជាប់ជាទាសកររួយជីវិត ព្រោះតែខ្លាចស្លាប់ » ។

(ហេប្រឺ ២:១៤-១៥)

«ដោយព្រះគ្រីស្តបានទទួលបណ្តាសាសំរាប់យើង ទ្រង់លោះយើង អោយរួចផុតពីបណ្តាសាដែលមកពីវិន័យ ដ្បិតមានចែងទុកមកថា÷ "អ្នកណាដែលត្រូវគេព្យួរជាប់នឹងឈើ អ្នកនោះត្រូវបណ្តាសាហើយ !"... យើងទទួលព្រះវិញ្ញាណ ដែលព្រះជាម្ចាស់បានសន្យាប្រទានមក ដោយយើងមានជំនឿ » ។

(កាឡាទី ៣:១៣-១៤)

នៅក្នុងរយៈពេលដ៏លំបាក ប៉ុន្តែ ពេញដោយសិរីរុងរឿងដ៏អស្ចារ្យ នៃប្រវត្តិសាស្ត្រសកលលោកទាំងមូលនេះ ព្រះយេស៊ូគ្រីស្តដែល ជាកូនចៀមឥតទោសរបស់ព្រះជាម្ចាស់ បានចេញផ្តែលោះបាបឱ្យ ពិភពលោកទាំងមូល ។ (១ ពេត្រុស ២:២៤, ១ យ៉ូហាន ២:២)

ការដែលវាំងននក្នុងព្រះវិហាររហែកជាពីរ តាំងពីលើដល់ក្រោម បង្ហាញថា ពេលនេះមានផ្លូវអាចចូល ទៅជិតព្រះជាម្ចាស់ដ៏វិសុទ្ធ បំផុតបានហើយ ។ (ម៉ាថាយ ២៧:៥១)





© Project WorldReach © SEAN

អាដាមអើយ អាដាម

អ្នកនៅឯណា ?



នៅពេលដែលព្រះយេស៊ូសុគត ដើម្បីយើង

ព្រះអង្គស្រែកថា÷



© Project WorldReach © SEAN



ពួកទាហាន និងពួកយូដា ព្រមទាំងពួកអារក្សផ្ទាល់
កំពុងធ្វើអោយផែនការដ៏អស់កល្បរបស់ព្រះជាម្ចាស់
បានសំរេច ទោះបីជាពួកគេមិនដឹងថា ពួកគេកំពុងធ្វើ
កិច្ចការនេះក៏ដោយ ។ (កិច្ចការ ២:២៣)

*ខ្ញុំសុខចិត្តស៊ូប្តូរជីវិត ដើម្បីឲ្យបានជីវិតនោះមកវិញ ។
គ្មាននរណាដកហូតជីវិតរបស់ខ្ញុំបានឡើយ គឺខ្ញុំស៊ូប្តូរ
ជីវិតដោយខ្លួនខ្ញុំផ្ទាល់តែម្តង ។*
(យ៉ូហាន ១០:១៧-១៨)



នរណាប្រាប់អ្នកអោយដឹងថា អ្នកនៅខ្លួនទទេដូច្នេះ ?

តើអ្នកបរិភោគផ្លែឈើដែលយើងហាមនោះ ឬ ?





© Project WorldReach © SEAN


ខ្ញុំជាចោរព្រៃឬ បានជាអស់លោកកាន់ដាវ
និងដំបងមកចាប់ខ្ញុំដូច្នេះ ?


គឺស្ត្រីនោះអោយផ្លែឈើនេះមកទូលបង្គំ
ហើយទូលបង្គំក៏បរិភោគទៅ ។



ពេលកំណត់ ដែលគេត្រូវចាប់ព្រះយេស៊ូ ដើម្បីធ្វើគុត ជិតមកដល់ហើយ ។ ព្រះយេស៊ូអធិស្ឋាននៅក្នុងសួនកេតសេម៉ានីលើភ្នំដើមអូលីវ ដោយព្រះទ័យព្រួយជាខ្លាំងបំផុត :



សាវ័ករបស់ព្រះអង្គនាំគ្នាសំរាន្តលក់អស់ ទើបពួកគេមិនបានឃើញក្បួនភ្លើងចន្លុះ ដែលកំពុងធ្វើដំណើរចេញពីទីក្រុងមកទេ ។

© Project WorldReach © SEAN

ទីបំផុត មារសាតាំងបានរកឃើញឱកាសសំរាប់យកឈ្នះលើព្រះយេស៊ូ ។ វាល្បងសាវ័កក្លែងក្លាយរបស់ព្រះ-យេស៊ូម្នាក់ ឈ្មោះយូដាសអ៊ីស្ការីយ៉ុត ឱ្យក្បត់ព្រះអង្គ គឺគាត់លក់ព្រះអង្គអោយពួកអ្នកដឹកនាំសាសនា ដែលច្រណែនឈ្នាណឹសព្រះអង្គ ដើម្បីអោយបានប្រាក់ ។



ឯងនឹងត្រូវបណ្តាសាហើយ ។ ឯងត្រូវតែលូននឹងពោះ... យើងនឹងធ្វើអោយឯង និងស្ត្រី ព្រមទាំងពូជឯង និងពូជស្ត្រីក្លាយទៅជាសត្រូវនឹងគ្នា ។ ពូជនាងនឹងជាន់ក្បាលរបស់ឯង ហើយឯងនឹងចឹកកែងជើងរបស់គេ ។



© Project WorldReach © SEAN

ឯនាងវិញ នាងនឹងសំរាលកូនទាំងឈឺចុកចាប់

ហើយប្តីនាងនឹងធ្វើជាម្ចាស់លើនាង...។



(កំណើតពិភពលោក ៣:១៦)



ប៉ុន្តែ ពួកអារក្សគ្មានទ្វានុភាពលើព្រះអម្ចាស់យេស៊ូទេ ។ ផ្ទុយទៅវិញ ព្រះអង្គដេញវាចេញពីមនុស្សទៀត :



មារសាតាំងខឹងខ្លាំងណាស់ ក៏ធ្វើការប្រជុំនៅស្ថាននរក ដោយស្រែកថា÷



គឺពិតជាវាហ្នឹងហើយ ដែលជាកូនរបស់ស្ត្រីដែលព្រះអង្គបានសន្យាជាមួយនឹងអាដាម និងនាងអេវ៉ានោះ ។ វាមកដើម្បីកំទេចពួកយើង ។ ប៉ុន្តែយើងនឹងកំទេចវាមុន ព្រោះមនុស្សត្រូវតែស្លាប់មែនទេ ! វាជាដង្កូវ ដែលកើតចេញពីមនុស្សស្រី ! យើងត្រូវតែប្រយុទ្ធប្រឆាំងនឹងវា !

ឯចំណែកអាដាមវិញ ! ដីនឹងត្រូវបណ្តាសា ព្រោះតែអ្នក ។ អ្នកត្រូវរកស៊ីចិញ្ចឹមជីវិតទាំងបង្ហូរញើសរហូត ដល់ថ្ងៃដែលអ្នកត្រឡប់ទៅជាដីវិញ ។

(កំណើតពិភពលោក ៣:១៧-១៩)



ហេតុនេះហើយ ដោយសារតែអាដាមដែលជាឪពុករបស់
មនុស្សជាតិមិនស្តាប់បង្គាប់ យើងរាល់គ្នាក៏បានទទួល :

ការឈឺចាប់...

ការអត់ឃ្លាន...

សេចក្តីស្លាប់...

ការជំនុំជំរះ...

ស្ថានមច្ចុរាជ...





© Project WorldReach © SEAN

ព្រះគ្រីស្តមានវ័យចំរើនឡើង ហើយបានទទួលពិធីជ្រមុជទឹកហើយ ។ ពេលនេះ ព្រះអង្គអធិស្ឋាន...



ហេតុនេះហើយបានជាសេចក្តីស្លាប់រាលដាលដល់មនុស្សគ្រប់រូប ព្រោះគ្រប់គ្នាសុទ្ធតែបានប្រព្រឹត្តអំពើបាប ។ (រ៉ូម ៥:១២)



មនុស្សជាតិទាំងមូលធ្លាក់ចុះដោយសារតែអាដាម ។



ព្រះជាម្ចាស់រាប់មនុស្សបាបគ្រប់គ្នាជាមនុស្សដែល
«ស្លាប់ព្រោះតែកំហុស និងអំពើបាបរបស់គេ» ។
(អេភេសូ ២:១)



ក្រោយមក...



ពួកហោរាចារ្យទាំងនោះយោកប្រាសយើងហើយ ។ ពួកគេមិនបានត្រឡប់មកប្រាប់យើងវិញទេ ! ចូរនាំគ្នាទៅបង្ហែហិមភ្លាម ហើយសម្លាប់ក្មេងប្រុសដែលមានអាយុតិចជាងពីរឆ្នាំចោលទាំងអស់ !

«មនុស្សលោកទាំងអស់ត្រូវស្លាប់តែមួយដង រួចត្រូវព្រះជាម្ចាស់វិនិច្ឆ័យទោស» ។ (ហេប្រឺ ៩:២៧)



© Project WorldReach © SEAN

ព្រះយេស៊ូមានព្រះបន្ទូលថា...

“ដល់ពេលកំណត់ មនុស្សស្លាប់ទាំងប៉ុន្មាន នឹងឮព្រះសូរសៀងរបស់ព្រះបុត្រា ហើយចេញពីផ្នូរមក ។ អ្នកដែលបានប្រព្រឹត្តអំពើល្អនឹងរស់ឡើងវិញ ដើម្បីទទួលជីវិត...” ។



បន្ទាប់មក ស្តេចហេរ៉ូដមានព្រះបន្ទូលប្រាប់ពួកហោរាចារ្យទាំងនោះថា÷





...រីឯអ្នកដែលបានប្រព្រឹត្តអំពើអាក្រក់នឹងរស់ឡើងវិញ
ដើម្បីទទួលទោស » ។ (យ៉ូហាន ៥:២៨-២៩)



© Project WorldReach © SEAN

តើនៅថ្ងៃជំនុំជំរះ កូនរបស់អាដាម (មនុស្សយើង) អាចនឹងមានសង្ឃឹមដូចម្តេច ?



ព្រះគម្ពីរចែងថា÷ « គ្រប់ៗគ្នាសុទ្ធតែបានប្រព្រឹត្តអំពើបាប ហើយគ្មានសិរីរុងរឿងរបស់ព្រះជាម្ចាស់នៅជាមួយ » ។ (រ៉ូម ៣:២៣)

ពិតមែនហើយ ប៉ុន្តែ ពួកទេវទូតរបស់សត្រូវយើងបានប្រកាសថាអញ្ចឹង ។ ព្រះសង្គ្រោះនោះ មិនមែនជាក្មេងធម្មតាទេ ។ ព្រះអង្គប្រសូតពីនាងព្រហ្មចារីយ៍ ។



មារសាតាំងក៏ប្រញាប់ទៅរាជវាំងរបស់ស្តេចហេរ៉ូដ... ។

នៅពេលនោះដែរ នៅស្ថានក្រោម...



មនុស្សបែកចេញពីព្រះជាម្ចាស់ ដោយសារអំពើបាបរបស់គេ ។ ព្រះជាម្ចាស់មិនដែលទុកអោយអំពើបាបនៅជាមួយព្រះអង្គទាល់តែសោះ សូម្បីតែអំពើបាបតូចបំផុតក៏ដោយ ។



© Project WorldReach © SEAN

ព្រះជាម្ចាស់ជាព្រះបិតា បញ្ជាទេវទូតដែលយាមទ្វារ
បាំងផ្លូវជីវិតថា÷



**"ក្រិត្យវិន័យដ៏នៅ
អស់កល្បរបស់យើង
គឺមនុស្សបាបមិនអាច
ចូលទៅក្នុងទីវិសុទ្ធជា
រៀងរហូត ។**

ក្រោយមក...



© Project WorldReach © SEAN

ដើម្បីអោយមនុស្សបានឆ្ងងផុតពីសេចក្តីស្លាប់ទៅរកជីវិត
អស់កល្បជាមួយព្រះជាម្ចាស់បាន ព្រះអង្គមានផែនការ
ចាត់ព្រះយេស៊ូគ្រីស្ត ឱ្យយាងមកក្នុងពិភពលោកនេះ
ដើម្បីធ្វើជាផ្លូវតែមួយ នាំមនុស្សទៅរកព្រះជាម្ចាស់ ។
សូមអានបន្តទៀត ដើម្បីអោយដឹងថាព្រះយេស៊ូគ្រីស្ត
បានយាងមក ដោយរបៀបណា ។...រាប់ពាន់ឆ្នាំក្រោយ
មក ព្រះវិញ្ញាណរួមជាមួយព្រះបិតា និង ព្រះបុត្រា
មានព្រះបន្ទូលថា÷

យើងនឹងបណ្តាលអោយនាងព្រហ្មចារីយ៍ម្នាក់ ដែលយើង
បានជ្រើសរើសនោះ មានផ្ទៃពោះ ។



ជញ្ជាំងដែលរារាំងមិនអោយមនុស្សបាប
ចូលទៅជិតព្រះជាម្ចាស់បាន ។



© Project WorldReach © SEAN

ព្រះជាម្ចាស់ជាព្រះបុត្រា មានបន្ទូលឆ្លើយតបថា÷

ថៃមួយ យើងនឹងចោះជញ្ជាំង ដែលរារាំងមិនឱ្យមនុស្សចាប
ចូលនោះ ធ្វើជាទ្វារចូលមួយ ។ យើងនឹងកើតជាមនុស្ស
ដើម្បីដកអំពើចាបចេញពីមនុស្ស ដោយសុគតជំនួសមនុស្ស
ចាបទាំងអស់នោះ ។



